**សំរាប់ចេញផ្សាយបន្ទាន់**

## ប្រទេសកម្ពុជា: ការកែប្រែថ្មីៗមួយទៅលើសេចក្តីណែនាំសំរាប់អ្នកធ្វើការតាមផ្ទះ កំណែរទំរង់គោលនយោបាយស្តីអំពីកម្មករទេសន្តរប្រវេសន៏មានភាពខ្សោយលើដំណើរការ នៃការជ្រើសរើសពលករ

(ញូវយក ថ្ងៃទី៣០ ខែសីហា ឆ្នាំ ២០១១) — តាមសេចក្តីរាយការណ៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិមួយនៅថ្ងៃនេះ លើកឡើងថាកំណែរទំរង់គោលនយោបាយស្តីអំពី កម្មករទេសន្តរប្រវេសន៏ ដែលអនុម័តដោយលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០១១មានឥទ្ធិពលតិចតួចបំផុតលើតម្រូវការនៃការការពារសុវត្ថិភាពដល់កម្មករទេសន្តរប្រវេសន៏។ អង្គការដដែលនេះបានបន្ថែមទៀតថា: កំណែរទំរង់គោលនយោបាយនេះ មិនមានមូលដ្ឋាន គ្រប់គ្រាន់ក្នុងការការពារសិទ្ធិកម្មករ និងដោះស្រាយបញ្ហារបស់ពួកគេដូចជា: ការជំពាក់បំណុលក្រុមហ៊ុន ការជ្រើសរើសពលករមិនគ្រប់អាយុដោយខុសច្បាប់ និង ការបង្ខាំងពលករដោយក្រុមហ៊ុនជ្រើសរើសកម្មករនៅក្នុងប្រទេសកម្ពុជា។

"អនុក្រឹត្យស្តីពី ការគ្រប់គ្រងលើ ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន " ត្រូវបានរៀបចំឡើងដោយគ្មានការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងកម្មករទេសន្តរប្រវេសន៏នោះទេ។

លោកស្រី Jyotsna Poudyal អ្នកស្រាវជ្រាវរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយថា: "រដ្ឋាភិបាលកម្ពុជាមិនបានអើពើ ពិភាក្សាជាមួយអង្គការជាតិ ឬអន្តរជាតិ ដែលកំពុងធ្វើការងារលើវិស័យនេះ ឬក៏ពិគ្រោះយោបល់ ជាមួយពលករនោះឡើយ"។" ជាលទ្ធផល ច្បាប់នេះមិនបានរួមចំនែកក្នុងការការពារទាល់តែសោះ ចំពោះផលប្រយោជន៏ពលករខ្មែរដែលទទួលរងការរំលោភបំពាន នៅពេលដែលពួកគេព្រមព្រៀងទៅបំរើការងារនៅបរទេស"។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានស្នើសុំដោយទទូចឱ្យរដ្ឋាភិបាលកម្ពុជាធ្វើការកែទំរង់ច្បាប់នេះ ឬបង្កើតគោលនយោបាយថ្មីដែលអាចជួយដោះស្រាយបញ្ហាចំបង៧របស់ពលករដូចជាៈ ប្រាក់ឈ្នួល សេវា និងប្រាក់បំណុល សេរីភាពក្នុងការធ្វើដំណើរពេលរស់នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល និង ការជ្រើសរើសពលករមិនទាន់គ្រប់អាយុ ជាដើម។ ច្បាប់នេះគួរតែត្រូវបានរៀបចំឡើងដោយធ្វើការ ពិគ្រោះយោបល់ជាមួយអង្គការជាតិ និង អន្តរជាតិ ដែលកំពុងតែធ្វើការលើវិស័យការពារសិទ្ធិពលករ និងការជួញដូរមនុស្សដោយដាក់ចេញនូវការកំនត់ទោសជាក់លាក់។

ពលករកម្ពុជាធ្វើចំណាកស្រុកដោយសារតែភាពអត់ការងារធ្វើនៅក្នុងស្រុករបស់ខ្លួន និងដើម្បីរកប្រាក់ផ្ញើត្រលប់មកផ្ទះវិញ។ ពលករទាំងនោះភាគច្រើនធ្វើចំណាកស្រុកទៅប្រទេសថៃ កូរ៉េខាងត្បូង និង ម៉ាឡេស៊ី។ អង្គការអន្តរប្រវេសន៍អន្តរជាតិ (IOM) បានប៉ាន់ប្រមាណថា ចំនួនពលករអន្តប្រវេសន៍កម្ពុជានៅក្នុងប្រទេសថៃមួយ មានចំនួន ២៤៨ ០០០ ក្នុងឆ្នាំ ២០០៨។ ពលករភាគច្រើន ជាពិសេសអ្នកធ្វើការងារតាមផ្ទះដែលចូលទៅប្រទេសម៉ាឡេស៊ី ច្រើនតែទទួលរងនូវការរំលោភបំពាន និងកេងប្រវ័ញ្ចដោយសារតែក្រុមហ៊ុនបញ្ជូនពលករទាំងនោះ ខ្វះការតាមដាន និងត្រួតពិនិត្យ ឱ្យបានត្រឹមត្រូវ។

ភ្នាក់ងាជ្រើសរើសពលករឯកជន និងអ្នករកស៊ីយកកំរៃជើងសារ (មេខ្យល់) ក្នុងស្រុក តែងតែខកខានមិនបានផ្តល់ពតិមានគ្រប់គ្រាន់ដល់ពលករដែលបានដាក់ពាក្យទៅធ្វើការ អំពីការបណ្តុះបណ្តាលរបស់ពួកគេប្រាក់ដែលត្រូវជំពាក់ក្រុមហ៊ុនសំរាប់សេវាជ្រើសរើស និងលក្ខខ័ណ្ឌក្នុងការបំរើការងារនៅក្រៅប្រទេសនោះទេ។ អ្នកមួយចំនួនទៀតបានជួយរៀបចំឯកសារក្លែងក្លាយដើម្បីបំពេញទៅតាមតម្រូវការច្បាប់របស់ប្រទេសម៉ាឡេស៊ី ដែលចែងថា អ្នកធ្វើការងារតាមផ្ទះត្រូវមានអាយុយ៉ាងតិច ២១ ឆ្នាំឡើងទៅ។ ពលករភាគច្រើនដែលបានឆ្លងដែនទៅប្រទេសម៉ាឡេស៊ី មានអាយុតិចជាង ១៨ ឆ្នាំ។ ស្ត្រី និង កុមារី ដែលជាពលករ តែងតែបង្វែរប្រាក់ខែរបស់ខ្លួន ៦-៧ ខែ ដំបូង សងថ្លៃសេវាជ្រើសរើសរបស់ក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជាវិញ។ នៅពេលដែលពួកគេ ត្រូវបានក្រុមហ៊ុន ព្រមព្រៀងទទួលឱ្យទៅធ្វើការហើយ ពួកគេត្រូវក្រុមហ៊ុន តម្រូវឱ្យ

ស្នាក់នៅ ក្នុងមណ្ឌលនៅក្នុងប្រទេសកម្ពុជា រាប់ខែ រហូតដល់ពេលចេញដំណើទៅកាន់ ប្រទេសម៉ាឡេស៊ី។ បើទោះបីជាពួកគេផ្លាស់ប្តូរចិត្តមិនទៅធ្វើការនៅប្រទេស ម៉ាឡេស៊ី វិញក៏ដោយ ក៏ក្រុមហ៊ុន តម្រូវឱ្យពួកគេបង់ថ្លៃសេវាជ្រើសរើសដែរ។ ពលករ ដែលមកពីក្រុមគ្រួសារក្រីក្រ មិនមានជម្រើសអ្វី ក្រៅពីការបង្ខំចិត្តរស់នៅក្នុងមណ្ឌលដ៏ចង្អៀត និង ចុះហត្ថលេខា លើកិច្ចសន្យា ទៅបំរើការងារតាមផ្ទះនៅប្រទេស ម៉ាឡេស៊ីនោះទេ។

លោកស្រី Poudyal បានបន្តទៀតថាៈ "រដ្ឋាភិបាលកម្ពុជា បានដឹងយ៉ាងច្បាស់ថា ក្រុមហ៊ុនជ្រើសរើសពលករឯកជនទាំងនោះ បានរំលោភលើសិទ្ធិពលករ បង្ខាំងពួកគេឱ្យរស់នៅក្នុងមណ្ឌលតូចចង្អៀត ទារប្រាក់ថ្លៃសេវាលើសកំណត់ និងតម្រូវឱ្យពួកគេបង់ការប្រាក់ថ្លៃជំពាក់យ៉ាងមិនអាម៉ាស់ទៀតផង "។ "ជាងនេះទៅទៀត ច្បាប់ថ្មីនេះ មិនបានជួយដោះស្រាយបញ្ហាខាងលើ ដែលជាការប្រើប្រាស់ពលកម្មដោយបង្ខំ និង ការជួញដូរទេ បែរជាដាក់បន្ទុក បន្ថែមទៅលើពលករទៅវិញ"។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយថា "ច្បាប់ថ្មីនេះធ្វើឡើងដើម្បីជំនួសអនុក្រឹត្យឆ្នាំ ១៩៩៥ លេខ ៥៧ ស្តីអំពី "ការបញ្ជូនពលករខ្មែរទៅធ្វើការងារនៅក្រៅប្រទេស"។ ច្បាប់នេះបានផ្តល់ការទទួលខុសត្រូវដល់

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងការត្រួតពិនិត្យលើភ្នាក់ងារជ្រើសរើសពលករឯកជន និងតម្រូវឱ្យក្រុមហ៊ុនផ្តល់មេធាវី ដល់ពលករ ក្នុងករណីមានបណ្តឹងស្របច្បាប់ នៅក្រៅប្រទេស និងធ្វើកិច្ចសន្យាការងារ ជាភាសាខ្មែរ រវាងក្រុមហ៊ុន និង ពលករ។ ច្បាប់នេះបានបញ្ជាក់ពី ស្តង់ដាររស់នៅសមស្របនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាល ប៉ុន្តែមិនបានកំណត់ពីតម្រូវការជាអាប្បរមានៃការរស់នៅនោះទេ។

ច្បាប់ថ្មីនេះបានបញ្ចូលឱ្យមានការពិន័យសំរាប់ការរំលោភរបស់ក្រុមហ៊ុន។ ការដាក់ពិន័យនេះ ចាប់ផ្តើមចេញពីការព្រមានជាលាយលក្ខអក្សរ និង រហូតទៅដល់ការដកអាជ្ញាប័ណអាជីវកម្ម។ ហើយក្រុមហ៊ុន អាចឈានទៅដល់ការបាត់បង់ប្រាក់ ដំកល់របស់ខ្លួនចំនួន ១០០ ០០០ ដូល្លាអាមេរិច ដែលក្រុមហ៊ុន បានដាក់ដំកល់

ជាមួយរដ្ឋាភិបាលនៅពេលចុះបញ្ជីពាណិជ្ជកម្ម។ ប៉ុន្តែ ច្បាប់នេះ មិនបានបង្កើតឱ្យមានយន្តការសំរាប់ដាក់ពាក្យបណ្តឹងនោះទេ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយទៀតថា: ច្បាប់នេះមិនបានបញ្ចូលបទដ្ឋានច្បាប់ជាច្រើន ដែលចែងនៅក្នុងអនុសញ្ញាស្តីពីការងារសមស្របរបស់ពលករដែលបំរើការងារតាមផ្ទះ របស់អង្គការ ពលកម្មអន្តរជាតិ និង សន្ធិសញ្ញាអន្តរជាតិ ដែលទទួលស្គាល់នៅ ខែមិថុនា ឆ្នាំ ២០១១។ មាត្រា ១៥ ចែងអំពីភ្នាក់ងារក្រុមហ៊ុនដែលរំលោភលើយន្តការនៃការដាក់ពាក្យបណ្តឹង ទំងន់ទោសចំពោះក្រុមហ៊ុន ដែលបានបំពានលើបទដ្ឋានពាក់ព័ន្ធនា នានិងការហាមឃាត់លើការកាត់ប្រាក់ខែសំរាប់ទូទាត់ថ្លៃសេវា។

លោកស្រី Poudyal បានបន្តទៀតថា: "រដ្ឋាភិបាលកម្ពុជា ត្រូវតែយកចិត្តទុកដាក់លើការការពារប្រជាពលរដ្ឋដែលប្រឈមនឹងការកេងប្រវ័ញ្ច និងការរំលោភបំពាននៅក្រៅប្រទេស ដើម្បីផ្តល់ទំនុកចិត្តដល់គ្រួសាររបស់ពួកគេ " ។ "ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និង សុវត្ថិភាពដល់ពលករ រដ្ឋាភិបាលត្រូវកំណត់នូវបទដ្ឋានអប្បរមា បង្កើតប្រព័ន្ធត្រួតពិនិត្យច្បាស់លាស់ និងបង្កលក្ខណៈឱ្យពលករមានលទ្ធភាពប្តឹងនៅពេលណា ដែលពួកគេទទួលរងនូវការរំលោភបំពាន។

សំរាប់ពត៌មានបន្ថែមពីរបាយការណ៍សិទ្ធិស្ត្រី របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស សូមចូលទៅគេហទំព័រ: http://www.hrw.org/category/topic/women

សំរាប់ពត៌មានបន្ថែមពីរបាយការណ៍ពីប្រទេសកម្ពុជា របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស សូមចូលទៅគេហទំព័រ : http://www.hrw.org/asia/cambodia

*សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនង:*

នៅញូវយក: Jyotsna Poudyal (English): +1-212-377-9437; +1-917-576-6969 (mobile); poudyaj@hrw.org
នៅញូវយក: Nisha Varia (English, Spanish): +1-212-216-1858; +1-917-617-1041 (mobile); or varian@hrw.org
នៅបាងកក: Phil Robertson (English, Thai): +66-85-060-8406 (mobile); or robertp@hrw.org